ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

លេខ ០០៦/ខ.ល.ម/២០១៧

# សារលិខិតរំលែកទុក្ខ

ជូន

ចំពោះលោកស្រី **តាន់ តារ័ត្ន** ភរិយាអនុសេនីយ៍ទោ **អ៊ឹម សំ**

លោកស្រី ជាទីរាប់អាន!

ក្នុងនាមនាយទាហាន នាយទាហានរង និងពលទាហាននៃកងយោធពលខេមរភូមិន្ទ ខ្ញុំមានសេចក្ដីរន្ធត់ក្រៀមក្រំជាទីបំផុត ដោយអនុសេនីយ៍ទោ អ៊ឹម សំ បុគ្គលិកបើកបរនៃកងវិស្វកម្មសំណង់លេខ៨៥៩ ក្នុងបេសកកម្មពហុភាគីរួមគ្នា នៃសហប្រជាជាតិ ដើម្បីស្ថេរភាពនៅសាធារណរដ្ឋអាហ្វ្រិកកណ្ដាល( MINUSCA) បានពលីជីវិត កាលពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ ២០១៧ វេលាម៉ោង២០:០០នាទី ដោយសារការលួចស្ទាក់វាយប្រហារពីក្រុមប្រដាប់អាវុធមួយក្រុម មកលើក្បួនយុទ្ធដំណើរកងកម្លាំងកម្ពុជា និងកងកម្លាំងប្រទេសម៉ារ៉ុក ។

ការបាត់បង់រូបអនុសេនីយ៍ទោ អ៊ឹម សំ គឺជាការបាត់បង់យោធិនមួយរូប ដែលបានលះបង់កម្លាំងកាយចិត្ត ដើម្បីបម្រើជាតិមាតុភូមិ និងប្រជាជន ក្នុងការចូលរួមចំណែកដោយស្ម័គ្រចិត្តក្នុងបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ក្នុងនាមមនុស្សធម៌ ។

ក្នុងក្របខណ្ឌនៃការបំពេញបេសកកម្មខាងលើ អនុសេនីយ៍ទោ អ៊ឹម សំ បានយកចិត្តទុកដាក់អនុវត្តការងារយ៉ាងសកម្ម ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីចូលរួមលើកកម្ពស់កេរ្តិ៍ឈ្មោះ កិត្តិយសជាតិមាតុភូមិ ពិសេស កងយោធពលខេមរភូមិន្ទលើឆាកអន្តរជាតិ ។

ក្នុងនាមខ្លួនខ្ញុំផ្ទាល់ នាយទាហាន នាយទាហានរង និងពលទាហាននៃកងយោធពលខេមរភូមិន្ទ សូមចូលរួមរំលែកនូវសេចក្ដីទុក្ខដ៏ក្រៀមក្រំក្ដុកក្ដួលអាឡោះអាល័យជាទីបំផុត ជាមួយលោកស្រី និងក្រុមគ្រួសារ ញាតិមិត្តទាំងអស់នៃសព និងសូមបួងសួងដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ តាមបីបាច់រក្សាដួងវិញ្ញាណក្ខន្ធអនុសេនីយ៍ទោ អ៊ឹម សំ បានទៅសោយសុខក្នុងសុគតិភព ជានិច្ចនិរន្តរ៍តរៀងទៅ ។

សូមលោកស្រី ទទួលនូវមនោសញ្ចេតនា ចែករំលែកទុក្ខដោយក្ដីក្រៀមក្រំបំផុតពីខ្ញុំ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៩ ខែឧសភា ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

នាយឧត្តមសេនីយ៍.ទៀ-បាញ់